នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសជ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃ៣០ ខែឧសភា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-May-2012, 09:17
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតក្នុងការផ្ដល់លិខិតធានាអះអាង អំពីការមិនចោទប្រកាន់ ដល់សាក្សីនានា

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តារា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G.KARNAVAS
គង់ សំអុន
Arthur VERCKEN
Jacques VERGES
Anta GUISSE

## I. សេចក្ដីផ្ដើម

១- សហព្រះរាជអាជ្ញា ស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្ដល់នូវលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ដូចដែលមាននៅក្នុងទម្រង់ក្នុង **ឧបសម្ព័ន្ធ** ក ដែលជូនភ្ជាប់មកជាមួយនេះ ស្រាប់ ដល់សាក្សីទាំងឡាយដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងសំណុំរឿងលេខ ០០២។

២- សហព្រះរាជអាជ្ញា សូមធ្វើការកត់សំគាល់ថា ការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ត្រូវបានលើកឡើងទាក់ទងទៅនឹងសាក្សីមួយចំនួន ដែលបានមកធ្វើសក្ខីកម្មរហូតមកទល់ពេលនេះ ហើយត្រូវបានអង្គជំនុំជម្រះលើកឡើងនៅក្នុងឈុតនៃការណែនាំមួយចំនួននាពេលថ្មីៗនេះ[1]។ ដោយផ្អែកលើមូលដ្ឋាននៃឆន្ទានុសិទ្ធិ សហព្រះរាជអាជ្ញាសូមស្នើផ្ដល់ជូននូវលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ចំពោះសាក្សីទាំងឡាយដែលមានការភ័យខ្លាចអំពីការចោទប្រកាន់ ដែលទាក់ទងនឹងព្រឹត្តការណ៍នានាដែលបានកើតមានឡើងនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ គោលបំណងនៃលិខិតធានាអះអាងនេះ គឺដើម្បីជួយឲ្យកិច្ចដំណើរការនៃសវនាការជំនុំជម្រះក្ដីបានប្រព្រឹត្តទៅដោយភាពឆាប់រហ័ស និងជួយលើកទឹកចិត្តឲ្យការផ្ដល់សក្ខីកម្មពីបណ្ដាសាក្សីនានាមានភាពទូលំទូលាយ និងពោរពេញទៅដោយការពិត បើពុំដូច្នោះទេ សាក្សីទាំងនេះនឹងមានការខ្លាចញញើតមិនហ៊ាននិយាយរឿងរ៉ាវ អំពីអង្គហេតុជាក់ស្ដែងដែលពាក់ព័ន្ធ បានពេញលេញតាមដែលពួកគេបានឃើញបានដឹងនោះឡើយ។

៣- លិខិតធានាអះអាងមិនចោទប្រកាន់ គឺជំរាបជូនដំណឹងចំពោះសាក្សី ដែលត្រូវបានចេញលិខិតឲ្យទាក់ទងនឹងព្រឹត្តការណ៍ដែលបានកើតឡើងនៅក្នុងអម្លុងពេលដូចខាងលើថា៖ (១) សហព្រះរាជអាជ្ញានឹងមិនធ្វើការផ្ដួចផ្ដើមចោទប្រកាន់ណាមួយប្រឆាំងចំពោះសាក្សីនោះឡើយ។ និង(២) អនុលោមតាមច្បាប់របស់កម្ពុជាបច្ចុប្បន្ន សាក្សីមិនអាចត្រូវបានចោទប្រកាន់ ដោយតុលាការជាតិកម្ពុជាណាមួយឡើយ។ សហព្រះរាជអាជ្ញា សូមសំណូមពរឲ្យមានការប្រគល់ជូនដល់សាក្សីនានានូវលិខិតធានាអះអាងអំពីការមិនចោទប្រកាន់នេះ ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។

[1] ឯកសារលេខ **E193**, ការណែនាំអនុលោមតាមវិធាន២៨ នៃវិធានផ្ទៃក្នុង (សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង) ចុះថ្ងៃទី១០ ឧសភា ២០១២។

## II. សេចក្តីត្រូវការចាំបាច់ឲ្យមានលិខិតធានាសុវត្ថិភាពអំពីការមិនចោទប្រកាន់

៤- នៅក្នុងករណីរឿងក្តីព្រហ្មទណ្ឌធំៗ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ថា ធ្លាប់បានកាន់កាប់តួនាទីជាន់ខ្ពស់នៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋាភិបាល, នយោបាយ, និង/ឬ កងទ័ព សាក្សីទាំងឡាយដែលអាចមានលទ្ធភាពផ្តល់នូវសក្ខីកម្ម ដែលមានភវនីយភាពខ្លាំងបំផុតបាននោះ គឺមានតែពួកអ្នកដែលទំនងប្រាកដជាធ្លាប់បានចូលរួមនៅក្នុងកំរិតណាមួយ ឬនៅក្នុងអ្វីមួយចំនួនដែលក្បែរៗនឹងបទឧក្រិដ្ឋដែរ។ ដោយសារគ្មានយន្តការសំរាប់លើកឡើងអំពីសេចក្តីព្រួយបារម្ភពីសំណាក់សាក្សីទាំងនេះនោះ គឺថាបើសិនជាសាក្សីទាំងនេះនិយាយចេញមកនូវការពិតទាំងស្រុងនោះ ពួកគេខ្លួនឯងផ្ទាល់អាចនឹងត្រូវប្រឈមមុខនឹងការចោទប្រកាន់ ដែលការខ្លាចញញើតរបស់សាក្សីនេះអាចជាឧបសគ្គរាំងយ៉ាងពិតប្រាកដណាស់ចំពោះការបញ្ជាក់អំពីការពិត។

៥- បញ្ហានេះត្រូវបានលើកឡើងដោយផ្នែកខ្លះនៅក្នុងវិធាន២៨ នៃវិធានផ្ទៃក្នុងសំរាប់ អវតក ដែល*ក្នុងចំណោមបញ្ហាដទៃៗជាច្រើនទៀត* គឺផ្តល់អំណាចទៅឲ្យអង្គជំនុំជម្រះអាចបង្ខិតបង្ខំសាក្សីឲ្យឆ្លើយនឹងសំណួរដែលចម្លើយនេះអាចលេចឡើងនូវបញ្ហាអំពីការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ផ្នែកខ្លះនៃវិធាននេះ គឺបានយកតាមគំរូនៃវិធាន៧៤ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង(RPE) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។ ក៏ប៉ុន្តែការកំរិតកំណត់ជាក់ស្តែងនៃវិធាននេះគឺថា វិធាននេះគ្រាន់តែយកមកអនុវត្តចំពោះកាលៈទេសៈនានាដែលក្នុងនោះមានសាក្សីណាម្នាក់បានបដិសេធមិនព្រមឆ្លើយតបនឹងសំណួរតែប៉ុណ្ណោះ។ វិធាននេះមិនបានលើកឡើងទាំងស្រុងអំពីចំនួនដ៏ច្រើន ដែលមានលក្ខណៈហ្មត់ចត់ជាង និងប្រហែលជាមានលទ្ធភាពធ្វើឲ្យខូចខាតច្រើនជាង ដែលក្នុងនោះដោយសារការភ័យខ្លាចអំពីការចោទប្រកាន់ ដែលអាចបង្ហាញចេញជាក់ស្តែងដើម្បីធ្វើឲ្យខូចខាតដល់ឆន្ទៈរបស់សាក្សីដែលចង់ផ្តល់ជូននូវសក្ខីកម្មឲ្យបានពេញលេញ និងដោយទៀងត្រង់។

៦- ឧទាហរណ៍ដូចជាវិធាន២៨ អាចមិនបានចែងអំពីស្ថានភាពមួយដែលក្នុងនោះមានសាក្សីម្នាក់បានឆ្លើយនឹងសំនួរដោយគ្មានការពិត និង/ឬ ដោយមិនព្រមផ្តល់នូវព័ត៌មានដែលមានភវនីយភាពក្នុងលក្ខណៈមួយដែលថា មិនឃើញច្បាស់ជាក់ស្តែងភ្លាមៗ ឬមួយក៏គ្រាន់តែធ្វើពុតថា ភ្លេចលែងចាំតែប៉ុណ្ណោះ។ នៅក្នុងកាលៈទេសៈដែលទាំងអង្គជំនុំជម្រះ ឬទាំងភាគីណាមួយក្នុងចំណោមភាគីនានាសុទ្ធតែមិនបានជួបជាមួយសាក្សីមុនពេលសាក្សីផ្តល់សក្ខីកម្មនោះ គឺវាមានការលំបាកជាទីបំផុតក្នុងការកំណត់សំរេចថា តើសាក្សីណាម្នាក់មិនអាចមានលទ្ធភាពផ្តល់ភស្តុតាងបាន ព្រោះដោយសារតែការភ្លេចភ្លាំង

លែងចាំ/ការមិនបានដឹង ឬមួយក៏មានមនសិកាមិនចង់ផ្តល់ភស្តុតាងដោយសារតែភ័យខ្លាចក្រែងមានការចោទប្រកាន់ដែរឬទេ? ការធានាអះអាងអំពីមិនចោទប្រកាន់ មានគោលដៅដើម្បីបំពេញការខ្វះចន្លោះនេះ ហេតុដូចនេះដើម្បីបំពេញបន្ថែមពីលើយន្តការទាំងឡាយដែលមានចែងនៅក្នុងវិធាន២៨ នៃវិធានផ្ទៃក្នុង។ នៅក្នុងពេលទន្ទឹមគ្នានេះ លិខិតធានាអះអាងអំពីការមិនចោទប្រកាន់មិនបានដាក់កំរិតតាមបែបណាមួយចំពោះសិទ្ធិអំណាចរបស់អង្គជំនុំជម្រះ មិនឲ្យប្រើប្រាស់វិធានការណ៍ទាំងនេះតាមដែលខ្លួនយល់ឃើញថាចាំបាច់អនុលោមតាមវិធាន២៨ ឬជាផ្នែកនៃសិទ្ធិអំណាចដែលមានជាប់ជាមួយស្រាប់របស់ខ្លួននោះទេ។

៧- វិធានជាធរមាននានានៅកំរិតអន្តរជាតិ បានចែងអំពីយុត្តិសាស្ត្រសំរាប់អនុវត្តតាមមួយ ក្នុងការផ្តល់នូវការធានាអះអាងអំពីការមិនចោទប្រកាន់ ជូនដល់សាក្សីទាំងឡាយដែលមានការភ័យខ្លាចអំពីការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មាត្រា៩៣(២) នៃលក្ខន្តិកៈរបស់តុលាការ ICC បានចែងថា៖

***មាត្រា៩៣***

***ទម្រង់ផ្សេងៗទៀតនៃកិច្ចសហប្រតិបត្តិការ***

> *២. តុលាការត្រូវមានសិទ្ធិអំណាចក្នុងការផ្តល់នូវការធានាអះអាងមួយ ចំពោះសាក្សី ឬអ្នកជំនាញណាម្នាក់ដែលចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការថា <u>រូបគេនឹងមិនត្រូវបានធ្វើការចោទប្រកាន់</u> ឃុំខ្លួន ឬដាក់ឲ្យស្ថិតនៅក្នុងការកំហិតសេរីភាពបុគ្គលណាមួយ <u>ដោយតុលាការនោះទេ ទាក់ទងនឹងអំពើ ឬការធ្វេសប្រហែសណាមួយ ដែលមានតាំងពីមុនការចាប់ផ្តើមចេញដំណើររបស់បុគ្គលនោះពីរដ្ឋដែលបានស្នើសុំ</u>។ (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត)*

៨- វិធាន១៩១ នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ ICC បានចែងបន្ថែមទៀត អំពីការណែនាំស្តីពីការអនុវត្តធានានុសិទ្ធិនៅក្នុងមាត្រា ៩៣(២)។ វិធាននេះបានចែងថា នៅពេលដែលតុលាការអាចផ្តល់នូវការធានាអះអាង ដោយផ្អែកលើញត្តិរបស់ខ្លួនផ្ទាល់ ឬលើពាក្យសុំដោយភាគី ឬសាក្សីណាម្នាក់ តុលាការអាចធ្វើដូច្នេះបាន លុះត្រាតែបន្ទាប់ពីបានយកចិត្តទុកដាក់លើយោបល់យល់ឃើញរបស់រដ្ឋអាជ្ញា និងសាក្សីដែលពាក់ព័ន្ធរួចហើយសិន តែប៉ុណ្ណោះ៖

***មាត្រា១៩១***

***ការធានាអះអាងដែលផ្តល់ដោយតុលាការតាមមាត្រា៩៣,កថាខណ្ឌទី២***

> *អង្គជំនុំជម្រះដែលត្រូវដោះស្រាយលើករណីរឿងនេះ ដោយផ្អែកលើញត្តិរបស់ខ្លួនឬ តាមសំណើសុំរបស់*

*រដ្ឋអាជ្ញា, សាក្សី ឬអ្នកជំនាញដែលពាក់ព័ន្ធ អាចធ្វើការសំរេច ក្រោយពីបានគិតគូរយកចិត្តទុកដាក់លើយោបល់របស់រដ្ឋអាជ្ញា និងសាក្សី ឬអ្នកជំនាញដែលពាក់ព័ន្ធ ដើម្បីផ្តល់នូវការធានាអះអាងដូចដែលបានរៀបរាប់នៅក្នុងមាត្រា៩៣ កថាខណ្ឌទី២។*

នៅពេលដែលការធានាអះអាងអំពីការមិនចោទប្រកាន់ដែលបានស្នើឡើងដោយ សហព្រះរាជអាជ្ញា មិនបានគ្រោងទុកអំពីការពិគ្រោះយោបល់ជាមួយសាក្សីនោះ សហព្រះរាជអាជ្ញាមិនមានការជំទាស់ចំពោះសាក្សីដែលកំពុងត្រូវបានធ្វើការពិគ្រោះយោបល់ នៅមុនពេលបានទទួលលិខិតធានាអះអាងនោះឡើយ។

៩- អត្ថិភាពនៃយន្តការខាងលើនេះ ដែលបន្ថែមទៅលើសិទ្ធិអំណាចរបស់តុលាការក្នុងការបង្ខិតបង្ខំសាក្សីនានាឲ្យឆ្លើយនឹងសំនួរផ្សេងៗ (ដូចដែលមានចែងនៅក្នុងវិធាន៧៤ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC) និងវិធាន២៨ នៃវិធានផ្ទៃក្នុង) ឆ្លុះបញ្ចាំងឲ្យឃើញពីសេចក្តីត្រូវការចាំបាច់ឲ្យមានវិធីសាស្ត្រច្រើនបែបច្រើនយ៉ាងដើម្បីដោះស្រាយលើបញ្ហាស្តីពីការខ្លាចក្រែងមានការចោទប្រកាន់របស់សាក្សីនេះ។

១០- លក្ខខណ្ឌនៃការធានាអះអាងអំពីការមិនចោទប្រកាន់នេះ ត្រូវបានលើកយកមកពិភាក្សាយ៉ាងលំអិតដូចមានខាងក្រោម។

## III. លក្ខខណ្ឌនៃការធានាអះអាងអំពីការមិនចោទប្រកាន់

១១- ផ្នែកទីមួយ នៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ គឺជាការធានាអះអាងមួយចំពោះសាក្សីដែលត្រូវបានគេបានផ្ញើឯកសារនេះទៅឲ្យថា សហព្រះរាជអាជ្ញា នឹងមិនផ្តួចផ្តើមធ្វើការការស៊ើបអង្កេតណាមួយ ប្រឆាំងនឹងពួកគេចំពោះព្រឹត្តិការណ៍នានាដែលបានកើតមានឡើងនៅក្នុងអម្លុងពេលពីឆ្នាំ១៩៧៥ ដល់១៩៧៩ នោះទេ។ វិធាន៤៩(១) នៃវិធានផ្ទៃក្នុងបានចែងថា ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋណាមួយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក អាចធ្វើឡើងបានតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ទោះបីជាការសំរេចចិត្តដោយឯកឯង ឬផ្អែកតាមពាក្យបណ្តឹងក៏ដោយ។ ផ្នែកទី១ នៃលិខិតអះអាងអំពីការមិនចោទប្រកាន់នេះ គឺផ្អែកលើអំណាចឆន្ទានុសិទ្ធិ។

១២-ផ្នែកទីពីរ នៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ បានជំរាបទៅដល់សាក្សីឲ្យបានជ្រាបថា អនុលោមតាមច្បាប់របស់កម្ពុជាបច្ចុប្បន្ន គឺពួកគេមិនអាចត្រូវបានធ្វើការចោទប្រកាន់ចំពោះព្រឹត្តិការណ៍ណាមួយ ដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ បានទេ។ ដោយសារតែការធានាអះអាងនេះ គឺជាការបន្ថែមពីលិខិតធានាអះអាងប្រឆាំងនឹងការចោទប្រកាន់នៅចំពោះមុខ អវតក គឺវាជួយគាំទ្រចំពោះគោលដៅតែមួយដូចគ្នា៖ ការធានាឲ្យមានកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញពីសាក្សី និងការផ្តល់លទ្ធភាពដល់តុលាការដើម្បីបញ្ជាក់អំពីការពិតដែលទាក់ទងទៅនឹងរាល់ការចោទប្រកាន់ខាងអង្គហេតុទាំងអស់ ដែលស្ថិតនៅចំពោះមុខអង្គជំនុំជម្រះ។ មូលដ្ឋានខាងអង្គច្បាប់សំរាប់សេចក្តីថ្លែងការណ៍នៅក្នុងផ្នែកទី២ នៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ មានផ្តល់ជូនដូចខាងក្រោមនេះ។

១៣-ដូចដែលសហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានពីដំបូងនៅក្នុងករណីនេះ គឺថាឧក្រិដ្ឋកម្មអន្តរជាតិមិនមានកំណត់អាជ្ញាយុកាលឡើយ[2]។ ចារីនៃបទឧក្រិដ្ឋទាំងនេះ អាចត្រូវបាននាំខ្លួនមកចំពោះមុខតុលាការក្នុងស្រុកនៅពេលណាមួយក៏បាន ឲ្យតែច្បាប់ក្នុងប្រទេសនោះបានអនុម័តឡើងដែលអនុញ្ញាតឲ្យមានការចោទប្រកាន់តាមប្រព័ន្ធច្បាប់របស់ប្រទេសនោះ[3]។

១៤- ក្នុងខណៈដែលច្បាប់ អ.វ.ត.ក និងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩[4] អនុញ្ញាតឲ្យមានការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិនៅកម្ពុជា តែច្បាប់ទាំងនេះមិនផ្តល់យុត្តាធិការទៅឲ្យតុលាការក្នុងស្រុកធម្មតាទាក់ទិននឹងឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ទេ។

---

[2] *សូមមើលឧទាហរណ៍* **D427/3/6** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៩ វិច្ឆិកា ២០១០, កថាខណ្ឌទី២០៣-២០៤។ គោលការណ៍ឆ្លុះបញ្ចាំងឲ្យឃើញក្នុងមាត្រា៩ *ក្នុងចំណោមមាត្រាផ្សេងទៀត* នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[3] *សូមមើលឧទាហរណ៍* **D427/3/6** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៩ វិច្ឆិកា ២០១០, កថាខណ្ឌទី១៣៤-១៣៥ (ដោយសន្និដ្ឋានថា ច្បាប់ អ.វ.ត.ក ជាច្បាប់លក្ខន្តិកៈដែលផ្តល់យុត្តាធិការនៅ អ.វ.ត.ក ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិ), កថាខណ្ឌទី១៣៩ (បែងចែក អ.វ.ត.ក ពីតុលាការធម្មតា) និងកថាខណ្ឌ ១៤១ (ពាក់ព័ន្ធជាមួយអំណះអំណាងរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលថា តុលាការក្នុងប្រទេសបារាំងបដិសេធមិនព្រមអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នៅពេលអវត្តមានបទប្បញ្ញត្តិរបស់ប្រទេសជាលាយលក្ខណ៍អក្សរ។ សូមអានផងដែរ **E51/5/3/1** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មរបស់មេធាវីការពារក្តី អនុលោមតាមវិធាន៩៨, ២១ មីនា ២០១១, កថាខណ្ឌទី៦ (សន្និដ្ឋានថា អ.វ.ត.ក អាចប្រើយុត្តាធិការបានយ៉ាងត្រឹមត្រូវទៅលើបទឧក្រិដ្ឋអន្តរជាតិ ដោយសារច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការនោះនៅក្នុងតុលាការនេះ)។

[4] សូមអានមាត្រា១៨៣ និងបទប្បញ្ញត្តិបន្តបន្ទាប់។

១៥- ច្បាប់ អ.វ.ត.ក ពាក់ព័ន្ធក្នុងសម័យកាលដូចបានបញ្ជាក់ពីខាងលើ ប៉ុន្តែ យុត្តាធិការរបស់វា គឺមានតែនៅ អ.វ.ត.ក ប៉ុណ្ណោះ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ដែលអនុញ្ញាតឲ្យមានការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិនៅចំពោះមុខតុលាការក្នុងស្រុកនោះ គ្មានប្រតិសកម្មនោះទេ។ និយាយម្យ៉ាងទៀត ច្បាប់នេះមិនលើកយកមកធ្វើការចោទប្រកាន់ចំពោះបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅមុនច្បាប់នេះបានចូលជាធរមានឡើយ។ ការណ៍នេះគឺច្បាស់ណាស់តាមរយៈមាត្រា៦៧១ *ក្នុងចំណោមមាត្រាផ្សេងៗទៀត* ដែលនៅជាធរមានសម្រាប់ការអនុវត្តច្បាប់ព្រហ្មទណ្ឌស្តីពីពេលវេលាកំណត់នៅមុនក្រមនេះចេញក្នុងឆ្នាំ២០០៩៖

***មាត្រា៦៧១: និរាករណ៍ និងអនុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន***

*ច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អនុភាពចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត៖*

*១- រាល់បទប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ១៩៩២។*

*២- បទប្បញ្ញត្តិព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។*

*...*

*យ៉ាងណាមិញ បទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដូចបានកំណត់ក្នុងកថាខណ្ឌ ៦៧១(១) និង៦៧១(២) ខាងលើត្រូវនៅបន្តមានអនុភាពទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅមុនការអនុវត្តក្រមនេះ ...*

១៦- បទប្បញ្ញត្តិដែលមានចែងអំពីបទឧក្រិដ្ឋក្នុងស្រុកនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បើមិនដូច្នោះទេ នឹងគ្របដណ្តប់ចំពោះអំពើព្រហ្មទណ្ឌដែលបានប្រព្រឹត្តក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩នោះ គឺជាកម្មវត្ថុនៃអាជ្ញាយុកាលដែលមានរយៈពេល១០ឆ្នាំ[5]។ ថ្វីបើអវត្តមាននៃសេចក្តីសម្រេចចិត្តជាចុងក្រោយអំពីសុពលភាពនៃការពន្យារអាជ្ញាយុកាលនេះសម្រាប់គោលបំណងនៃ អ.វ.ត.ក ក្តី (តាមមាត្រា៣(ថ្មី)នៃច្បាប់ អ.វ.ត.ក) រយៈពេលកំណត់សម្រាប់បទឧក្រិដ្ឋក្នុងស្រុក ពេលនេះគឺវាអស់សុពលភាពហើយសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះតុលាការកម្ពុជាទាំងអស់ ទាក់ទិននឹងបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តនៅមុន ឬនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ដើម្បីភាពពេញលេញ គេបាន

[5] មាត្រា១០៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

កត់សំគាល់ថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៩២ របស់អ៊ុនតាក់ (UNTAC) គឺមានវិពឹងទុកសម្រាប់ការអនុវត្ត ហើយដូចគ្នានឹងក្រមឆ្នាំ១៩៥៦ដែរ ច្បាប់នេះពុំមានបទប្បញ្ញត្តិណាមួយសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិឡើយ។

១៧- ផ្នែក២ នៃលិខិតធានាមិនធ្វើការចោទប្រកាន់ គឺបានពឹងផ្អែកទៅលើភាពប្រាកដប្រជាផ្លូវច្បាប់ខាងលើ ដូចជាច្បាប់កម្ពុជាបច្ចុប្បន្ន មិនមានចែងអំពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យឆ្នាំ១៩៧៥-១៩៧៩ នៅចំពោះមុខតុលាការក្នុងស្រុកឡើយ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា វាជាការសមស្របដែលត្រូវជម្រាបជូនសាក្សីអំពីគោលជំហរច្បាប់នេះ ដោយគិតគូរដល់ផលប៉ះពាល់ផ្ទុយពីនេះដោយសារការភ័យខ្លាចគ្មានមូលហេតុអំពីការចោទប្រកាន់ ដែលអាចមាននៅក្នុងការស្វែងរកការពិតឲ្យបានពេញលេញនៅចំពោះមុខ អ.វ.ត.ក។ នៅខណៈដែលការពិតរដ្ឋសភាកម្ពុជាអាចនឹងអនុម័តច្បាប់ដែលអនុញ្ញាតឲ្យមានការចោទប្រកាន់នៅក្នុងស្រុកក៏ដោយ ក៏រហូតមកដល់ពេលនេះ សហព្រះរាជអាជ្ញាមិនបានដឹងអំពីសំណើច្បាប់ណាមួយដូច្នេះដែរ។

១៨- អង្គជំនុំជម្រះបានបញ្ជាក់នៅពេលថ្មីៗនេះថា តុលាការផ្តល់ទីប្រឹក្សាច្បាប់ដល់គ្រប់សាក្សីទាំងអស់ដែលបានស្នើសុំ ឬដែលគេគិតថា មានតម្រូវការ[6]។ ដូចអង្គជំនុំជម្រះបានដឹងរួចហើយថា ក្នុងខែសីហា ឆ្នាំ២០១១ ទាំងការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យផ្នែកការពារក្តី (DSS) ត្រូវបានអង្គភាពគាំពារសាក្សី និងអ្នកជំនាញ អញ្ជើញឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលសម្រាប់មេធាវីដែលនឹងត្រូវផ្តល់ប្រឹក្សាសម្រាប់សាក្សីនៅចំពោះមុខ អ.វ.ត.ក។ ក្នុងវគ្គបណ្តុះបណ្តាលនេះ ការិយាល័យសហព្រះរាជអាជ្ញា បានផ្តល់តាមការយល់ឃើញរបស់ខ្លួនអំពីច្បាប់កម្ពុជា ដូចបានបញ្ជាក់ពីខាងលើ ដោយពុំមានការមិនឯកភាពពីអ្នកចូលរួមណាម្នាក់ក្នុងវគ្គបណ្តុះបណ្តាលនេះឡើយ រួមទាំង DSS ផង។ បើសិនជាអង្គជំនុំជម្រះពិចារណាថាវាជាការសមស្រប សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការផ្តល់ច្បាប់ចម្លងនៃសំណើនេះមួយច្បាប់ ឬសេចក្តីសង្ខេប ជូនទីប្រឹក្សាច្បាប់ដែលកំពុងជួយសាក្សី ហើយដែលសាក្សីនេះបានទទួលលិខិតធានាមិនធ្វើការចោទប្រកាន់រួចហើយ។

---

[6] **E193**, *ដដែលដូចខាងលើ* កំណត់សំគាល់លេខ១។

១៩- ដើម្បីជាប្រយោជន៍នៃភាពត្រឹមត្រូវយុត្តិធម៌ សហព្រះរាជអាជ្ញាក៏សូមថ្លែងជូនផងដែរថា ខ្លួនមានឆន្ទៈពិចារណាក្នុងការចេញ លិខិតធានាមិនធ្វើការចោទប្រកាន់ ដល់សាក្សីណាក៏ដោយ រួមទាំងសាក្សីដែលអង្គជំនុំជម្រះសម្រេចកោះហៅតាមសំណើរបស់មេធាវីការពារក្តីផងដែរ។

២០- ជាចុងក្រោយ សហព្រះរាជអាជ្ញាធ្វើការកត់សំគាល់ (ភាគច្រើនជាទ្រឹស្តី) អំពីលទ្ធភាពនៃការចោទប្រកាន់ដែលអាចនឹងកើតមានក្នុងប្រទេសដទៃទៀត នៅក្រោមគំនិតនៃយុត្តាធិការជាសាកលនេះគ្រាន់តែជាសេណារីយោដាច់ស្រយាលមួយប៉ុណ្ណោះ (បើតាមការយល់ដឹងរបស់សហព្រះរាជអាជ្ញា វាមិនធ្លាប់កើតមានទាល់តែសោះតាំងពីឆ្នាំ១៩៧៩មក) ដែលថា ការមិនដាក់បញ្ចូលក្នុងលិខិតធានាមិនធ្វើការចោទប្រកាន់ គិតថាជារឿងមិនចាំបាច់នោះ។

## IV. ដំណោះស្រាយដែលស្នើ

២១- សហព្រះរាជអាជ្ញាសូមរំលឹកថា ដូចបានឆ្លុះបញ្ចាំងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក គោលបំណងជាគន្លឹះមួយនៃការបង្កើត អ.វ.ត.ក គឺដើម្បីដោះស្រាយការព្រួយបារម្ភពេញច្បាប់របស់ប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួមជាតិ[7]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា គោលបំណងទាំងនេះអាចសម្រេចទៅបានវៀរលែងតែថៅក្រមតុលាការនេះ អាចស្តាប់រឿងរ៉ាវឲ្យបានពេញលេញ និងគួរឲ្យជឿបានពីបុគ្គលនិមួយៗទាំងនោះដែលអង្គជំនុំជម្រះបានជ្រើសរើសជាសាក្សី។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការផ្តល់ជូនការធានា និងព័ត៌មានទាំងឡាយដែលមាននៅក្នុងលិខិតធានាមិនធ្វើការចោទប្រកាន់ គឺស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌។

២២-សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា សាក្សីទាំងអស់ រួមទាំងសាក្សីទាំងឡាយដែលទទួលបានលិខិតធានាមិនធ្វើការចោទប្រកាន់ បន្តប្រើសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ដែលបានកំណត់ក្នុងវិធាន ២៨(១) ហើយការផ្តល់នូវភាពកក់ក្តៅនេះ គឺមានអាណត្តិអនុលោមតាមវិធាន២៨(២)។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា នៅពេលណាដែលលិខិតធានាមិនធ្វើការចោទប្រកាន់ត្រូវបានប្រគល់ជូនសាក្សីរួចហើយ អាចជាការសមស្របដើម្បីបន្ថែមការទទួលស្គាល់ការធានាមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯងឲ្យកាន់តែមានភាពកក់ក្តៅ។ សហព្រះរាជអាជ្ញាស្នើថា ឃ្លាដែលគួរប្រើមានអានុភាពដូចតទៅៈ

[7] កិច្ចព្រមព្រៀង, បុព្វកថា។

*លោក/លោកស្រីមានសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ដែលមានន័យថា លោក/លោកស្រីមិនតម្រូវឱ្យនិយាយអ្វីដែលអាចប្រឆាំងនឹងខ្លួនឯងទេ។ ប៉ុន្តែ អង្គជំនុំជម្រះកត់សម្គាល់ឃើញដែរថា លោក/លោកស្រីបានទទួលលិខិតធានាមិនធ្វើការចោទប្រកាន់ពីការិយាល័យសហព្រះរាជអាជ្ញា ហើយលិខិតធានាមិនធ្វើការចោទប្រកាន់ជាច្បាប់ថតចម្លងដែលមានចុះហត្ថលេខានោះត្រូវបានរក្សាទុកនៅក្នុងសំណុំរឿង។*

២៣- ដូចមូលហេតុបញ្ជាក់ពីខាងលើ សហព្រះរាជអាជ្ញា ស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យសហព្រះរាជអាជ្ញា ៖

ក) ផ្តល់ជូននូវការធានាតាមទម្រង់ដូចមានចែងក្នុង **ឧបសម្ព័ន្ធ** ក ជូនដល់សាក្សី។

ខ) ដាក់លិខិតធានាមិនធ្វើការចោទប្រកាន់ ដែលបានចុះហត្ថលេខា ទៅក្នុងសំណុំរឿង ដើម្បីធានាអំពីតម្លាភាពនៃការប្រើប្រាស់លិខិតនេះ និងដើម្បីឱ្យមានជាកំណត់ហេតុផ្លូវការសម្រាប់ជាផលប្រយោជន៍របស់សាក្សី ហើយនិង

គ) បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ប្រគល់លិខិតធានាមិនធ្វើការចោទប្រកាន់ដែលបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញារួចជូនដល់សាក្សីឱ្យបានឆាប់តាមដែលអាចធ្វើទៅបានមុនពេលសាក្សីរូបនោះ បង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

២៤- ជាចុងក្រោយ ប្រសិនបើអង្គជំនុំជម្រះសម្រេចទទួលយកញត្តិនេះ សហព្រះរាជអាជ្ញាស្នើថា ការទទួលស្គាល់លិខិតធានាមិនធ្វើការចោទប្រកាន់ ត្រូវបានផ្តល់ជូនបន្ថែមពីការធានាឱ្យកាន់តែមានភាពកក់ក្តៅចំពោះការមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌ ២២ខាងលើ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |